## ១-លក្ខណៈទូទៅ

ដំណាំល្មុតគឺជាប្រភេទដើមឈើធំ និង មានស្លឹកខៀវស្រងាត់ពេញមួយរដូវ។ វាមានកម្ពស់រហូតដល់៣០ម និងមានអង្កត់ផ្ចិត១.៥ម៉ែត្រ ។ ការដាំដុះអាចប្រែប្រួលពីចន្លោះ ៩ ទៅ ១៥ ម៉ែត្រអាស្រ័យទៅនឹង (គំលាតដើម) លក្ខណៈភូមិសាស្ត្រ ។ មែករបស់វាបែកមែកសាខា ហើយគល់របស់វាមានរាងជាស៊ីឡាំងទ្រវែង ជាពិសេសដើមដុះនៅទោលតែឯង។ សម្បករបស់វាមានសម្បុរត្នោតចាស់ និងមានស្នាមប្រេះតូចៗ។ ឫសរបស់វា ជាប្រភេទប្រព័ន្ធឫសសាំញ៉ាំ។ ស្លឹករបស់វាជាប្រភេទស្លឹកធ្លាស់ ហើយតម្រៀបគ្នានៅលើ shoot tips ។

## ២.ការធ្វើចំណាត់ថ្នាក់របស់រុក្ខជាតិ

សណ្ឋាន :Sapotaceae

អំបូរ :Manilkara/Achras

ប្រភេទ :Zapota

ឈ្មោះវិទ្យាសាស្ត្រ :Manilkara Zapota / Achras Zapota

ឈ្មោះអង់គ្លេស :Sapodilla, Naseberry, Sapota ។ ទីកន្លែងដាំដុះតំបន់ត្រូពិច។ :

## ៣.លក្ខណៈរូបសាស្ត្រ

ក.កម្ពស់ដើម អាចឈានដល់កម្ពស់៣០ម បែកមែកសាខាពណ៌ត្នោតចាស់ ការលូតលាស់យឺតមានជ័រពណ៌ស ។

ខ.ស្លឹកៈបណ្តោយចាប់ពី៣,៥ស.មដល់១៥ស.ម ទទឹង១,៥ស.ម ដល់ ៧ស.មស្លឹកខ្ចីមានពណ៌លឿងត្នោតខ្ចី ស្លឹកចាស់មានពណ៌ត្នោតចាស់ ស្លឹកមានលក្ខណៈរលោងក្រាស់ជាប្រភេទស្លឹកធ្លាស់។

គ.ផ្កាៈ ពេលវេលាចេញផ្កា គឺចេញស្ទើររាល់ខែផ្កាមានលក្ខណៈជាចង្កោម ហើយមានពណ៌សមានរាងដូចជួង និងមាន៦ត្របក។

ឃ.ផ្លែៈ មាននៅខែមេសា និងសីហាមានរាងមូល និងទ្រវែងមានប្រវែងចាប់ពី៣ស.មដល់៨ស.ម ។ នៅពេលទុំផ្លែមានពណ៌លឿងត្នោត សាច់ខាងក្នុងមានពណ៌លឿងត្នោតមានរសជាតិផ្អែមឆ្ងាញ់។

ង.គ្រាប់ៈ នៅក្នុងមួយផ្លែមានគ្រាប់ពី ២-៥គ្រាប់ រាងសំប៉ែតទ្រវែង ស្រួចសងខាងបណ្តោយគ្រាប់ប្រវែង២ស.ម ទទឹងគ្រាប់មានប្រវែង ចាប់ពី១ស.ម ដល់ ២ស.ម សំបកគ្រាប់មានភាពរឹងរលោងពណ៌ក្រម៉ៅឬពណ៌ខ្មៅ។

## ៤. ពូជល្មុត

ក.ពូជធម្មតា ឬល្មុតណាំងបាយស្រៈ ផ្លែវាធំល្មមរាងទ្រវែងផ្លែ៤ទៅ៥ដងក្នុងមួយឆ្នាំ។

ខ.ល្មុតណាំង ឬល្មុតណាំងថ្ម ឬល្មុតថ្មៈ ផ្លែល្អិតៗ ប៉ុន្តែរឹងវាផ្លែ២ទៅ៣ដងក្នុងមួយឆ្នាំ ។

គ.ល្មុតពូជចឹកកាយ៉ាំង ឬល្មុតតាខ្មៅៈ ផ្លែធំៗ វាផ្លែ៤ទៅ៥ដងក្នុងមួយឆ្នាំ ប៉ុន្តែពុំសូវមានរសជាតិឆ្ងាញ់ទេ។ គេនិយមប្រើប្រាស់វានៅក្នុងពិធីមង្គលការនិងបុណ្យទានផ្សេងៗ។

ឃ.ល្មុតណាំងប៉ែន ឬល្មុតណាំងខ្សាច់ៈ ផ្លែមានរាងដូចផ្លែចាន់ប៉ែន សាច់វាទន់ជ្រាកៗបន្តិច ផ្លែវាធំជាងល្មុតធម្មតាបន្តិច វាផ្លែ៤ទៅ៥ដងក្នុងមួយឆ្នាំ។

## ៥. លក្ខខណ្ឌដី

ដំណាំល្មុត អាចដាំបាននៅលើប្រភេទដីកណ្តោងដីឥដ្ឋ ដីខ្សាច់ ដីអាស៊ីត ដីបាស ដីល្បាយខ្សាច់ មានដីជាតិ និង ស្រោះទឹកPH ចាប់ពី៥,៥ ដល់ ៦ ។

## ៦. អាកាសធាតុ

ដំណាំល្មុតអាចដាំបាន គឺអាកាសធាតុតំបន់ត្រូពិច ចំពោះដើមចាស់វាអាចទ្រាំបាននៅសីតុណ្ហភាពដក៣,៣៣ អង្សាសេ ដល់ ដក២,២អង្សាសេ។

## ៧. ការរៀបចំដី និងរណ្តៅដាំល្មុត

- យើងត្រូវភ្ជួរហាលដីទុកចោលចំនួន ១ ទៅ១ខែកន្លះសិន ដើម្បីអោយងាប់សត្វល្អិតនិង ស្មៅរលួយបានល្អ ។ យើងត្រូវភ្ជួរដីមួយលើកទៀតនៅពេលដែលជិតដាំកូនល្មុត។
- យើងត្រូវទាញខ្សែអោយត្រង់ ដើម្បីងាយស្រួលក្នុងការដាំដំណាំផ្សេងទៀត ។
- ចន្លោះពីដើមមួយទៅដើមមួយមានប្រវែង៥ម៉ែត្រ
- កាប់រណ្តៅទំហំ៤តឹកបួនជ្រុង និងជំរៅ៤តឹក កាប់យកអាចម៍ដីចេញពាក់កណ្តាលរណ្តៅ រួចទើបកាប់បំផុសអាចម៍ដី ដែលនៅសល់ឲ្យម៉ដ្ឋ រួចដាក់លាយជាមួយដីអាចម៍គោពុកផុយល្អ ។ ត្រូវហាលរណ្តៅទុកចោល២ទៅ៣ថ្ងៃមុនដាំ។

## ៨.ការដាំកូនល្មុត

- យើងត្រូវយកមែកល្មុត(មែកសាក) នៅក្បែររណ្តៅជាមុនសិន។
- យកមែកល្មុតសាកមកត្រាំទឹកឲ្យសើមបន្តិច។
- ស្រាយកញ្ចប់ផ្លាស្ទិចចេញយឺតៗ ដោយថ្នមៗ និង